**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ៤៩៧........ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តឧត្តរមានជ័យ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ



អគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៥ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តឧត្តរមានជ័យ សម្រាប់ធ្វើការគ្រប់គ្រងតាមលក្ខណៈសហគមន៍ព្រៃឈើ ប្រកបដោយនិរន្តរភាព ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើអន្លង់វែង ផ្នែករដ្ឋបាលព្រៃឈើបន្ទាយអំពិល និងផ្នែករដ្ឋបាលព្រៃឈើសំរោង នៃខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍន៍ព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និង ជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍នេះមានព្រៃសហគមន៍ចំនួន ១២ កន្លែង ដែលមានផ្ទៃក្រឡាសរុប ចំនួន ៦០.៤៧៧ (ហុកសិបពាន់បួនរយចិតសិបប្រាំពីរ) ហិកតា ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ១ នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយចំណុចគោល និង និយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និង ការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើ នៅក្នុងតំបន់ព្រៃសហគមន៍ដែលបានកំណត់ក្នុងប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម និង ប្រធានអង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តឧត្តរមានជ័យ
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ២ : ភ្ជាប់ប្រកាសលេខ..[illegible]..ប្រកសក ចុះថ្ងៃទី..១៩......ខែ....វិច្ឆិកា.......ឆ្នាំ ២០០៨

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តឧត្តរមានជ័យ

| លរ | ឈ្មោះសហគមន៍ | ផ្ទៃដី(ហិកតា) | ចំនុចនិយាមកា | ចំនួនភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|
| ១ | រតនៈរុក្ខា | ១២.៨៧២ | ជើង A (353210,1574999) B (358469,1576984)<br>C (362854,1575032)<br>ត្បូង C (362854,1575032) A (353210,1574999)<br>កើត A0 (367193,1569328) A1(367103,1559620)<br>A2 (364996,1557820)<br>ត្បូង A2 (364996,1557820) B0 (365000,1560000)<br>B1 (359855,1560000) B2 (359855,1557082)<br>B3 (358413,1556900) B4 (357000,1559813)<br>លិច B4 (357000,1559813) C0 (357000,1563450)<br>C1 (358422,1563225) C2 (358632,1565795)<br>C3 (355517,1565742) C4 (355376,1564230)<br>C5 (352014,1564230) C6 (351976,1570000)<br>ជើង C6 (351976,1570000) D0 (359000,1570000)<br>D1 (358993,1568806) D2 (362379,1569083)<br>D3 (361662,1573802) D4 (363384,1573700) | ១៦ | - សំរោង<br>- កូនក្រៀល | សំរោង | សំរោង |
| ២ | ឬស្សីស្រស់សំរស់ប្រាសាទផ្លុង | ៨៥០ | កើត A (357989,1588141) B (358008,1583008)<br>ត្បូង B (358008,1583008) C (355935,1584578)<br>លិច C (355935,1584578) D (356675,1589304)<br>ជើង D (356675,1589304) A (357989,1588141) | ២ | កូនក្រៀល | សំរោង | សំរោង |
| ៣ | ឈូកមាស | ៣៨៣ | កើត A (371604,1579367) B (371604,1578589)<br>ត្បូង B (371604,1578589) C (369730,1578503)<br>D (369610,1575331) E (368046,1577152)<br>លិច E (368046,1577152) F (369283,1578162)<br>G (368645,1578984)<br>ជើង G (368645,1578984) A (371604,1579367) | ១ | កូនក្រៀល | សំរោង | សំរោង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | អូរយាយកែវ | ៥៦០ | កើត<br>ត្បូង<br>លិច<br>ជើង | A (350684,1594174)<br>B (351638,1590300)<br>C (350660,1589081)<br>D (348959,1594306) | B (351638,1590300)<br>C (350660,1589081)<br>D (348959,1594306)<br>A (350684,1594174) | ១ | កូនក្រៀល | សំរោង | សំរោង |
| ៥ | រំដួលវាសនា | ៦.០១៦ | កើត<br>ត្បូង<br>លិច<br>ជើង | A (341379,1593012)<br>B (340001,1586727)<br>C (329974,1582999)<br>D (329974,1590316) | B (340001,1586727)<br>C (329974,1582999)<br>D (329974,1590316)<br>A (341379,1593012) | ៤ | បន្សាយរាក់ | សំរោង | សំរោង |
| ៦ | ភ្នំដងរែកសំរែក<br>ព្រៃស្រស | ១.៦០៤ | កើត<br>ត្បូង<br>លិច<br>ជើង | A (329972,1590320)<br>B (329972,1584023)<br>C (323440,1587032)<br>D (327770,1588808) | B (329972,1584023)<br>C (323440,1587032)<br>D (327770,1588808)<br>A (329972,1590320) | ២ | គោកខ្ពស់ | បន្ទាយអំពិល | បន្ទាយអំពិល |
| ៧ | អណ្ដូងបរ | ៦.១១៤ | កើត<br><br>ត្បូង<br>លិច<br>ជើង | B (312483,1549341)<br><br>D (313956,1543949)<br>E (306347,1541329)<br>A (302896,1548148) | C (314538,1547400)<br>D (313956,1543949)<br>E (306347,1541329)<br>A (302896,1548148)<br>B (312483,1549341) | ៨ | បេង | បន្ទាយអំពិល | បន្ទាយអំពិល |
| ៨ | ដុងបេង | ១.៨៤៣ | កើត<br><br>ត្បូង<br>លិច<br><br>ជើង | A (322202,1554651)<br><br>C (323020,1551352)<br>D (315832,1552269)<br><br>F (317058,1554169) | B (324537,1553463)<br>C (323020,1551352)<br>D (315832,1552269)<br>E (315877,1552873)<br>F (317058,1554169)<br>A (322202,1554651) | ៤ | បេង | បន្ទាយអំពិល | បន្ទាយអំពិល |
| ៩ | សាមគ្គី | ១.០៧៥ | កើត<br>ត្បូង<br>លិច<br>ជើង | A (386727,1584299)<br>B (387983,1581019)<br>C (384389, 1581298)<br>D (384162, 1584911) | B (387983,1581019)<br>C (384389, 1581298)<br>D (384162, 1584911)<br>A (386727,1584299) | ៤ | ត្រពាំងតាវ | អន្លង់វែង | អន្លង់វែង |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១០ | អូរតគីគីរីព្រៃស្រោង | ៦.៣៤៤ | កើត<br>ត្បូង<br>លិច<br>ជើង | A (389864,1557383)<br>B (393246,1546388)<br>C (379044,1551185)<br>D (382386,1554729) | B (393246,1546388)<br>C (379044,1551185)<br>D (382386,1554729)<br>A (389864,1557383) | ៤ | លំទង | អន្លង់វែង | អន្លង់វែង |
| ១១ | សាមគ្គីសង្គ្រោះព្រៃឈើ | ៤.១៥១ | កើត<br>ត្បូង<br>លិច<br>ជើង | A (400009,1556324)<br>B (405040,1552165)<br>C (394520,1548264)<br>D (394409,1551897) | B (405040,1552165)<br>C (394520,1548264)<br>D (394409,1551897)<br>A (400009,1556324) | ៣ | អន្លង់វែង | អន្លង់វែង | អន្លង់វែង |
| ១២ | សង្ឃសហគមន៍រុក្ខាវ៉ន | ១៨.២៦១ | កើត<br>ត្បូង<br>លិច<br><br>ជើង | A (377666, 1573146)<br>B (377916, 1558644)<br>C (369321, 1556428)<br><br>E (367702, 1573895) | B (377916, 1558644)<br>C (369321, 1556428)<br>D (365936, 1562644)<br>E (367702, 1573895)<br>A (377666, 1573146) | ៥ | - ត្រពាំងតាវ<br>- លំទង | អន្លង់វែង | អន្លង់វែង |
| | សរុប | ៦០.៤៧៧ | | | | ៥៤ | ០៨ | ០៣ | ០៣ |

ឧបសម្ព័ន្ធ ១ ៖ ភ្ជាប់ប្រកាសលេខ...៤៨៧...ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តឧត្ដរមានជ័យ

